BreastScreen
Victoria

## សូមធ្វើការណាត់ជួបជាមុននៅ **breastscreen.org.au** ឬហៅទូរស័ព្ទទៅកាន់លេខ **13 20 50**

សម្រាប់ព័ត៌មានបន្ថែម៖
**breastscreen.org.au**

សូមហៅទូរស័ព្ទទៅកាន់លេខ **13 20 50** និងសុំឲ្យគេភ្ជាប់ទៅ BreastScreen Victoria

ព័ត៌មានដែលបានបកប្រែ៖
breastscreen.org.au/**translations**

**TTY 13 36 77** ប្រសិនបើអ្នកមានការពិបាកក្នុងការស្តាប់ និងនិយាយ។

VICTORIA State Government

BreastScreen Victoria ទទួលស្គាល់ការគាំទ្ររបស់រដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា។

2019

BR11/1223

Khmer | ភាសាខ្មែរ

# សូមទុកសុខភាព **របស់**អ្នកជាចំបង

## សូមធ្វើការណាត់ជួបពិនិត្យដោះរបស់អ្នកជាមុន



## សូមធ្វើការណាត់ជួបជាមុននៅ **breastscreen.org.au** ឬហៅទូរស័ព្ទទៅកាន់លេខ **13 20 50**

BreastScreen
Victoria

## តើខ្ញុំអាចនឹងមានជំងឺមហារីកដោះឬទេ?

ស្ត្រី **1នាក់ក្នុងចំណោម 7**នាក់ក្នុងរដ្ឋវិចតូរីយ៉ានឹង កើតជំងឺមហារីកដោះក្នុងអំឡុងជីវិតរស់នៅរបស់ ពួកគេ។



ស្ត្រីភាគច្រើនបំផុតដែលមានជំងឺមហារីកដោះ **មិនមាន**ប្រវត្តិគ្រួសារមានជំងឺនេះទេ។



**អាយុ**ជាកត្តាគ្រោះធំជាងគេបំផុតនៃការកើតជំងឺ មហារីកដោះ។




## ការពិនិត្យដោះ

- មិនគិតថ្លៃ។
- ចំណាយពេលប្រហែល **10**នាទី។
- មិនត្រូវការសំបុត្របញ្ជូនរបស់វេជ្ជបណ្ឌិតទេ។
- ធ្វើដោយគ្រូពេទ្យថតស្ត្រី។
- មាននៅគ្លីនិកក្បែរអ្នកនៅទូទាំងរដ្ឋវិចតូរីយ៉ា។

## តើអ្វីទៅជាការពិនិត្យដោះ?

ការពិនិត្យដោះ (ហ្វីលថតដោះ) គឺជារូបភាពថតដោះ ដោយប្រើកាំរស្មីអ៊ិក្ស។ ការពិនិត្យដោះអាចរកឃើញ ជំងឺមហារីកដែលមានទំហំតូចពេកដែលមិនអាច មើលឃើញ ឬស្ទាបដឹង។ ស្ត្រីកាន់តែច្រើនឆ្លងរួចពី ជំងឺមហារីកដោះក្នុងពេលបច្ចុប្បន្ននេះដោយសារ ការរកឃើញជាមុន និងការព្យាបាលល្អជាងមុន។

## តើខ្ញុំត្រូវការពិនិត្យដោះឬទេ?

ការរកឃើញជាមុនជួយសង្គ្រោះជីវិត។

### អាយុ 50-74?

អ្នកគួរទៅពិនិត្យរាល់ពីរឆ្នាំម្តង។

### តើអ្នកមានអាយុ 40 ឬ 40 ជាង ឬជាង 75ឆ្នាំឬទេ?

និយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នកដើម្បីឲ្យដឹងថា ការពិនិត្យដោះត្រឹមត្រូវសម្រាប់អ្នក។

### អាយុក្រោម 40ឆ្នាំ?

ការពិនិត្យដោះមិនមានប្រសិទ្ធភាពសម្រាប់ស្ត្រីអាយុ ក្រោម 40 ឆ្នាំទេ។

## សូមយល់ដឹងពីដោះ

- សូមយល់ដឹងពីសភាពធម្មតា និងការស្ទាបមើល នៃដោះ។ សូមជួបវេជ្ជបណ្ឌិតរបស់អ្នក ប្រសិន បើអ្នកកត់សម្គាល់ឃើញថាមានការប្រែប្រួល ខុសពីធម្មតាណាមួយ។
- សូមសួរវេជ្ជបណ្ឌិតរបស់អ្នកអំពីគ្រោះនៃជំងឺ មហារីកដោះរបស់អ្នក និងតម្រូវការដើម្បី ពិនិត្យ។

## សូមធ្វើការណាត់ជួបជាមុននៅ **breastscreen.org.au** ឬហៅទូរស័ព្ទទៅកាន់លេខ **13 20 50**